អំពីចលនាកន្សែងស

ឬ

# រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម

## The Struggle Front of the Khmer of Kampuchea Krom (KKK)

តាមប្រភពពត៌មាន នៃក្រសួងការកិច្ចយោធាអាមេរិកាំងនៅឯយៀកណាមខាងត្បូង បានឲ្យដឹងថា *រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម* បានត្រូវគេបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ ១៩៦១ ចេញពី <<**ចលនាកន្សែងស**>> ដែលជាក្រុមតស៊ូកើតឡើង ដោយសិស្សគណៈរបស់ព្រះសង្ឃខ្មែរស្នេហាជាតិមួយក្រុម ដែលធ្លាប់មានទំនាក់ទំនងជិតស្និត ជាមួយចលនាស្នេហាជាតិខ្មែរជាន់ដើមមួយមានឈ្មោះថា <<**ចលនានគរវត្ត**>> ដែលបានកកើតឡើងនៅអំឡុងឆ្នាំ១៩៣៥

ឥស្សរៈជនមួយចំនួន ដែលគេបានស្គាល់ឈ្មោះដូចជា៖ **ភិក្ខុ ជួន ណាត, ភិក្ខុ ហួត តាត, ភិក្ខុ អ៊ុក ជា, ភិក្ខុ ហែម ចៀវ, អាចារ្យ នួន ដួង, ប៉ាច ឈឿន, សឺង ង៉ុក ថាញ់, បួរ ហ៊ាង, ស៊ឹម វ៉ា, ប៊ុន ចន្ទម៉ុល** ជាដើម ។ល។

សូមជម្រាបថា ឥស្សរៈជនដែលបានជម្រាបឈ្មោះខាងលើនេះ មានមួយចំនួនបានគាំទ្ររាជវង្ស **នរោត្តម** ដែលកាលនោះ ពួកលោកបានគិតថារាជវង្ស **ស៊ីសុវត្ថិ** បានក្លាយជាឧបករណ៍ របស់អាណានិគមនិយមបារាំង ហើយរាជ្យសម្បត្តិនៃរាជានិយមខ្មែរ សមតែត្រូវសមាជិកនៃរាជវង្ស **នរោត្តម** ជាអ្នកដែលគួរតែទទួលឡើងសោយរាជ្យ ។

**សឺង ង៉ុក ថាញ់, ប៉ាច ឈឿន, បួរ ហ៊ាង, ស៊ឹម វ៉ា** ជាដើមសុទ្ធតែបានលំអៀងទៅគាំទ្រព្រះរាជវង្ស **នរោត្តម** ។ កាសែតខ្មែរដំបូងមួយ ដែលពួកនេះបានបោះពុម្ពផ្សាយក៏បានទទួលការជួយឧបត្ថម្ភ ពីសំណាក់សមាជិកនៃរាជវង្ស **នរោត្តម** ដែរ ។ (Justin Corfield and
Presss, Inc. 2003.)

នៅឆ្នាំ១៩៥១ **ស៊ឹង ង៉ុក ថាញ់** បានបែកចេញឈប់គាំទ្ររាជវង្ស **នរោត្តម** ពីព្រោះលោកមានទំនាស់ជាមួយនឹងសម្តេច **នរោត្តម សីហនុ** ដែលកាលនោះស្រាប់តែកើតមានចិត្តច្រណែននឹង **សឺង ង៉ុក ថាញ់** ដោយសារតែលោកមានប្រជាប្រិយ៍ខ្ពស់ត្រដែត ។

អ្នកដែលបានចេញធនធាន និងអនុញ្ញាតឲ្យរៀបចំចងក្រង <<**ចលនាកន្សែងស**>> ឲ្យក្លាយទៅជា **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** គឺសម្តេច **នរោត្តម សីហនុ** ដែលកាលនោះព្រះអង្គយល់ឃើញថាត្រូវតែចាត់តាំងក្រុមមួយ ទៅប្រជែងនឹង **ក្រុមខ្មែរសេរី** ដឹកនាំដោយ

សឹង ផុក ថាន់ ។ (Gerald Cannon Hickey, **Free in the Forest: Ethnohistory of the Vietnamese Central Highlands, 1954-1976.** New Haven: Yale University Press, 1982. p 61, *citing an original document given him by* KKK *leaders in Phnom Penh in 1970.*)

ទីបញ្ជាការដ្ឋានសម្ងាត់របស់ រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម តាំងនៅឯក្រុងភ្នំពេញ នៃកម្ពុជាកណ្តាល ។ មេបញ្ជាការនៃ រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម មានឈ្មោះថា <<ចៅ ដារ៉>> ឬ <<ចៅ ដារ៉>> ។ គោលបំណងដែលរណសិរ្សបានប្រកាសជាសម្ងាត់នោះគឺមានបំណងចង់ទាមទារមកវិញ នូវដែនទឹកដីអាណាខេត្តខ្មែរទាំងឡាយ នៅកម្ពុជាក្រោម ។ (5th Special Forces Group (Airborne), First Special Forces: *Outlines History of Company D, 1962-1970.* p 3)

# អំពីមេដឹកនាំខ្លះនៃចលនាកន្សែងស

តាមប្រភពមួយបាននិយាយថា ចៅ ដារ៉ នេះគឺជាមេបញ្ជាការនៃ រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម តែមិនមែនជាស្ថាបនិកនៃ ចលនាកន្សែងស ដំបូងនោះទេ ។

តាមរយៈ Arthur J. Dommen ក្នុងសៀវភៅរបស់លោកឈ្មោះ <<**ពិសោធន៍របស់បារាំង និង អាមេរិកាំង នៅឥណ្ឌូចិន, លទ្ធិជាតិនិយម និងលទ្ធិកុម្មុយនីស្ត នៅកម្ពុជា ឡាវ និង វៀតណាម** >> បោះពុម្ពផ្សាយនៅឆ្នាំ២០០១ ត្រង់ទំព័រ ៦១៥ បាននិយាយថា ស្ថាបនិកដំបូងនៃ ចលនាកន្សែងស គឺព្រះសង្ឃព្រះនាម **សំឱក សែន** ជាអ្នកបួសចេះមន្តអាគមគាថា ប្រកបដោយមហិទ្ធិឫទ្ធិខ្លាំងពូកែម្នាក់ នៅឯតំបន់ភ្នំប្រាំពីរ នៃដែនដីសណ្តរទន្លេមេគង្គ ។

តាមរយៈសេចក្តីរាយការណ៍ផ្នែកចារកិច្ច នៃក្រសួងស៊ើបការយោធារបស់កងកម្លាំងពិសេសអាមេរិកាំង បានកំណត់ឲ្យដឹងថាស្ថាបនិក នៃ ចលនាកន្សែងស ដំបូងគឺជាបព្វជិតអ្នកបួសមួយអង្គព្រះនាម **ស្នួត សេង** ឬ **ស្នួត សែង** ដែលអក្សរឡាតាំងសរសេរថា Smout SENG ដែលឮថាចេញមកពីតំបន់ភ្នំជិន ខេត្តកំពត នៃប្រទេសកម្ពុជា ។

ចំណែកឯ **ចៅ ដារ៉** វិញ មានប្រភពចេញមកពីភ្នំពេញ ដែលប្រភពពត៌មានខ្លះបាននិយាយថាធ្លាប់បានបួសរៀនមួយរយៈ ក្នុងសំណាក់ព្រះពុទ្ធសាសនា ។ ក្រោយសឹកពីបួស **ចៅ ដារ៉** បានចូលរួមជាមួយ ចលនាកន្សែងស របស់គ្រូ **សំឱក សែន** ហើយនៅឆ្នាំ១៩៦១ **ចៅ ដារ៉** បានត្រូវគេតែងតាំងជាមេបញ្ជាការ នៃ រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម ដែលពួកអាមេរិកាំងបានហៅតាមអក្សរកាត់ឡាតាំងថាពួក **KKK** ។

ប្រភពពត៌មានដដែលនេះនិយាយថាគឺគ្រូ **សំឱក សែន** ជាអ្នកណែនាំ **ចៅ ដារ៉** ទៅឲ្យស្គាល់វដ្តអំណាចនៅក្រុងភ្នំពេញ ហើយក៏បានទទួលការគាំទ្រពីសំណាក់វដ្តអំណាចនោះ ។ ប្រភពដដែលនិយាយថា អ្នកធំមានអំណាចខ្លាំងខ្ពស់បំផុតនៅឯភ្នំពេញជាអ្នកគាំទ្រ

ចៅ ដក់ ឲ្យដឹកនាំ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម ។

រដ្ឋអំណាចនៅភ្នំពេញ បានបញ្ចេញនូវការគាំទ្ររបស់ខ្លួនចំពោះ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម ដោយចំហរ ដោយបានទាំងបោះពុម្ពផ្សាយ នូវសារពត៌មានភាសាខ្មែរចំនួនពីរ ១ ឈ្មោះ **សច្ចំមនុស្ស** និង ១ ទៀតឈ្មោះ **សម្លេងខ្មែរក្រោម** ផ្សាយដំណឹងទាក់ទងអំពីស្ថានការណ៍ទូទៅ នៃបណ្តាជនជាតិខ្មែរនៅកម្ពុជាក្រោម ។

ក្រោយពីការបង្កើត រណសិរ្សសេរីខ្មែរកម្ពុជាក្រោម បានជិតមួយខែមក នៅខែធ្នូ ឆ្នាំ១៩៦១ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម បានបង្កើតសាខារបស់ខ្លួននៅខេត្តបី ក្នុងដែនដីកម្ពុជាក្រោម (យៀកណាមខាងត្បូង) គឺនៅ ហាទៀង នៃខេត្តគៀងយ៉ាង, នៅ ទ្រីតុន នៃខេត្តចូវ ដុក, និងនៅឯ ឡុកប៊ិញ នៃខេត្តប៊ិញឡុង ។ (យើងសូមអភ័យទោសនូវការខុសឆ្គងអចេតនា ដោយការបកប្រែភាសាពីបារាំង, អង់គ្លេស មកជាភាសាខ្មែរ) ។

នៅខែមិនា ឆ្នាំ១៩៦២ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម បានបង្កើតសាខារបស់ខ្លួននៅឯខេត្តតាយនិញ និងសាខាតូចៗមួយចំនួននៅតាមទីដែលមានខ្មែររស់នៅ ។

ទំនាក់ទំនងដំបូងនៃ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម ជាមួយអាជ្ញាធរយៀកណាមខាងត្បូង និងជាមួយនឹងផ្នែកកងពិសេសអាមេរិកាំង បានចាប់ផ្តើមតាំងពីថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ នៅពេលនោះ ចៅ ដក់ បានត្រូវចាប់ខ្លួន ដោយទាហ៊ានយៀកណាមខាងត្បូង នៅឯ ទ្រីតុន ឯខេត្ត ចូវដុក ។ សភាពរបស់ ចៅ ដក់ នៅពេលនោះកំពុងតែធ្លាក់ខ្លួនឈឺដោយជម្ងឺគ្រុនចាញ់ មិនអាចរត់គេចទៅណារួចឡើយ ។

ក្រោយពីពួកយៀកណាមខាងត្បូងចាប់បាន ចៅ ដក់ មក រណសិរ្សសេរីខ្មែរកម្ពុជាក្រោម បានធ្លាក់ក្រោមការដឹកនាំរបស់ ចៅ យ៉ែម ។ នៅដើមឆ្នាំ១៩៦៤ សក្តិបី ចៅ សុកាន ជាសមាជិកនៃ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម នៅ ចូវដុក បានអន្ទងឲ្យរណសិរ្សនេះចូលដៃជាមួយរដ្ឋការយៀកណាមខាងត្បូង ប៉ុន្តែខាង ចៅ យ៉ែម មិនព្រមចុះចូលទេ ។

នៅដើមឆ្នាំ១៩៦៥ ចៅ យ៉ែម បានចាកចេញពីជួរ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម ហើយការគ្រប់គ្រងរណសិរ្សក៏បានធ្លាក់ទៅលើ ចៅ អ៊ូច ។

ចៅ អ៊ូច នេះ បើតាមសេចក្តីវិភាគប្រវត្តិរូបរបស់ក្រសួងចារកិច្ចបានឲ្យដឹងថា ចៅ អ៊ូច ធ្លាប់ធ្វើទាហ៊ានបារាំងពាក់ដោយ ៣ ជាន់ ។ ក្រោយមក គាត់បានរត់ចេញពីអង្គភាពកងទ័ពបារាំង ទៅចូលជាមួយយៀកមិញ ហើយក្រោយមកបានចូលទៅបំរើយៀកកុង មុននឹងត្រូវគេបញ្ចូលឲ្យមកធ្វើការនៅឯ រណសិរ្សសេរីខ្មែរកម្ពុជាក្រោម ។

ពេលនោះ សក្តិបី ចៅ សុកាន ក៏បានបបួល ចៅ អ៊ូច ឲ្យចូលដៃជាមួយនឹងរដ្ឋការយៀកណាមខាងត្បូងផងដែរ ហើយ ចៅ អ៊ូច និងស្មគ្រ័បក្សពួកចំនួន ១៣៤ នាក់ មាន

អាវុធ ៥៨ ដើម ក៏បាននាំគ្នាចុះចូលជាមួយរដ្ឋការយៀកណាមខាងត្បូងនៅថ្ងៃទី ២៩ ដល់ទី ៣១ ខែកក្កដា ឆ្នាំ១៩៦៥ ។ ពួក ១៣៤ នាក់ហ្នឹង បានត្រូវរដ្ឋការយៀកណាមខាងត្បូង បញ្ចូលទៅក្នុងកងសន្តិសុខតំបន់ នៃខេត្ត ចូវដុក ដែលមាន **ចៅ អ៊ុច** មេបញ្ជាការ ។

នៅថ្ងៃទី ៥ ដល់ទី ១៣ ខែសីហា ឆ្នាំ១៩៦៥, ពួកកងពិសេសអាមេរិកាំងបានទាក់ទងជាមួយនឹង **ចៅ ហៀន** មេបញ្ជាការរណសិរ្សមួយផ្នែកទៀត ដែលជាគូរប្រជាំងគ្នាជាមួយនឹង **ចៅ អ៊ុច** មានទីតាំងនៅឯ ទិញបៀន Tinh Bien ឲ្យចុះចូលជាមួយរដ្ឋការយៀកណាមខាងត្បូង ។ **ចៅ ហៀន** បានយល់ព្រម ហើយគាត់និងស្ម័គ្របក្សពួកចំនួន ៦២៦ នាក់ អាវុធ ៧៤ ដើម បានចុះចូលជាមួយរដ្ឋការក្រុងព្រៃនគរ ។ (តាមប្រភពមួយទៀតនិយាយថាកាលណោះ **ចៅ ហៀន** បាននាំកូនចៅបក្សពួកចំនួន ៤៥០ ចុះចូលនឹងរដ្ឋការយៀក - ណាមខាងត្បូង ដែលជាចំនួនខុសគ្នាពីចំនួន ៦២៦ នាក់ខាងលើ) ។

**ចៅ ហៀន** បានត្រូវរដ្ឋការក្រុងព្រៃនគរតែងតាំងជាមេបញ្ជាការ នៃកងវរៈសេនាតូចមួយដែលមានសុទ្ធតែបក្សពួកកូនចៅគាត់ ហើយត្រូវបញ្ជូនឲ្យទៅហ្វឹកហាត់ មុខវិជ្ជាការយោធា និងវិន័យបន្ថែម នៅឯជុំរុំ Ba Xoai ។

តាមរយៈការទាក់ទងដែលមាន **ចៅ សុកាន** ពីមុនពាក់សក្តិបី ដល់មកឆ្នាំ១៩៦៦ បានឡើងបុណ្យសក្តិជាសក្តិបួន ដោយសារតែគាត់ពូកែខាងបញ្ចុះបញ្ចូលឲ្យពួក **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** ចុះចូលជាមួយយៀកណាមខាងត្បូង, សក្តិបួន **ចៅ សុកាន** បានណែនាំឲ្យពួកទីប្រឹក្សាអាមេរិកាំង នៃកងពិសេស ទៅជួបនឹង **ថាច់ ស** ជាមេបញ្ជាការម្នាក់ទៀត នៃ **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** នៅឯខេត្ត ចូវដុក ។ កាលណោះ មិនមានសេចក្តីរាយការណ៍ណាមួយ និយាយអំពីលទ្ធផលនៃការជួបគ្នានេះទេ ។

នៅខែមិនា ឆ្នាំ១៩៦៦ សក្តិបី **ចៅ កេត** ដែលមានបក្សពួកប្រហែល ៦០០ នាក់ បានជួបទាក់ទងគ្នាជាមួយភ្នាក់ងារសម្ងាត់យួនខាងត្បូង ។ ការជួបគ្នានោះមិនបានសំរេចជោគ-ជ័យទេ តែបានបើកផ្លូវឲ្យមានទំនាក់ទំនងបន្តទៅទៀត ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៦៦ ពួក **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** បីនាក់បានជួបគ្នាជាមួយនឹងសក្តិបួន **ចៅ សុកាន** ។ ការជួបនោះ បានទំលាយឲ្យមានការចុះចូល នៃពួករណសិរ្សចំនួន ៣៨ នាក់ ក្រោមការដឹកនាំរបស់ **ចៅ សឹង** នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ១៩៦៧ ។

ត្រឡប់មកនិយាយអំពី **ចៅ ដរ៉** ម្តង ។ យើងមិនដឹងថាមានសភាពការណ៍ដូចម្តេចទេ ក្រោយដែលគាត់បានត្រូវយៀកណាមខាងត្បូងចាប់ខ្លួនបាន ។ តែមានសេចក្តីរាយការណ៍មួយ បាននិយាយអំពីឈ្មោះគាត់ ថាគាត់បានកំពុងតែធ្វើសកម្មភាព

នៅឯតំបន់ភ្នំប្រាំពីរ នៃដែនដីសណ្តរទន្លេមេគង្គ នៅក្នុងឆ្នាំ១៩៦៧ ។

សេចក្តីរាយការណ៍ដដែលនិយាយថា នៅថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៦៧ កងពិសេសអាមេរិកាំង USASF Mobile Guerilla from MGF 489 បានទាក់ទងទៅកាន់ **ចៅ ដក់** នៅតំបន់ភ្នំប្រាំពីរ ហើយបានបបួលគាត់ឲ្យធ្វើការជា មួយនឹងពួកកងពិសេសអាមេរិកាំង ។

កិច្ចចរចារគ្នាបានធ្វើជាច្រើនដង រវាងពួកកងពិសេសអាមេរិកាំង ជាមួយនឹងពួកខាង **ចៅ ដក់** ដោយមានទំនាក់ទំនងល្អបង្គួរ ប៉ុន្តែខាងអាមេរិកាំងមិនបានទទួលលទ្ធផលគួរជាទីគាប់ចិត្តឡើយ ។ ម្ល៉ោះហើយ ពួកកងពិសេសអាមេរិកាំងក៏បានងាកទៅទាក់ទងជាមួយនឹងពួកមេបញ្ជាការ នៃ **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** ផ្សេងទៀតនៅក្នុងតំបន់នោះ ដូចជាទាក់ទងជាមួយនឹងក្រុម **ថាច់ ញុត**, **ថាច់ ពេញ**, និង **ចៅ ញួង** ជាដើម ។ល។

យើងបានដឹង តាមរយៈសេចក្តីរាយការណ៍ផ្សេងៗមួយចំនួន បាននិយាយថា **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** មានគណៈកម្មាធិការគាំទ្រ និង អភិបាល មួយដែលមានទីតាំងនៅឯកម្ពុជាកណ្តាល ។ គណៈកម្មាធិការនោះមានមន្ត្រីជាន់ខ្ពស់ នៃរដ្ឋាភិបាលក្រុងភ្នំពេញជាសមាជិក ដែលនៅក្នុងនោះមាន ឧត្តមសេនីឯក **លន់ ណល់** នៅក្នុងនោះផង ។

ប្រភពវិភាគផ្នែកយោធា នៃក្រុមស៊ើបការណ៍អាមេរិកាំង ដែលបានចាប់អារម្មណ៍តាមដាន និងសិក្សាវិភាគអំពីពួក **KKK** ឬ **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** នេះ បានប៉ាន់ស្មានឲ្យដឹងថាពួក **រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម** គ្រប់អង្គភាពទាំងអស់មិនមានកំឡាំងប្រដាប់អាវុធ ប្រកបដោយប្រសិទ្ធភាព ខាងចម្បាំងឡើយ មុនពេលដែលពួកនោះ បានត្រូវប្រូបាច់បញ្ចូលទៅក្នុងកម្មវិធី **CIDG** (Civilian Irregular Defence Group).

---------------------------------

# SPECIAL FORCE INSIGNIA




Cambodian-made SF patch.

សញ្ញានេះសំរាប់សំគាល់ទាហានខ្មែរបំរើនៅក្នុងកងកម្លាំងពិសេសអាមេរិកាំង ។ គឺរូបដាវមានរន្ទះបីពណ៌លឿង រីមក៏មានពណ៌លឿងដូចគ្នា ដេរលើក្រណាត់ពណ៌បៃតងចាស់ ។



ទាហាន<រណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម> (KKK) កាលពីដំបូងដែលគឺមានជួតក្បាលកន្សែងយ័ន្តពណ៌-ស ។ ក្រោយមកគេបានស្គាល់កងទ័ពនេះថា «កងទ័ពកន្សែង-ស» ។




សញ្ញានេះសំរាប់សំគាល់ទាហានខ្មែរបំរើនៅក្នុងកងកម្លាំងពិសេសអាមេរិកាំង ប្រចាំក្រុមទី៥ ដែលមានទីតាំងនៅក្នុងខេត្តតៃនិញប្រទេសយួនខាងត្បូង ។ ក្រុមនេះធ្វើការជាមួយកងកម្លាំងពិសេសលេខ A-303 និង 957 ។




សញ្ញានេះសំរាប់សំគាល់ កងទ័ពរណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម ។ អក្សរនៅពីលើសញ្ញាសរសេរថា «កងខេមរជាតិលេខ១ទ័ពឆ្នក់» ។




បេរ៉េនៃកងកម្លាំងពិសេសខ្មែរសំរាប់សំគាល់បុគ្គលិកប្រចាំការនៅបញ្ជាការដ្ឋានកណ្តាលទិសខាងជើងប្រទេសកម្ពុជា (ជំនាន់សាធារណរដ្ឋខ្មែរ) ។




សញ្ញានេះសំរាប់សំគាល់ទាហាននៃចលនាកន្សែង-ស បំរើនៅក្នុង «កងទ័ពតយុទ្ធ» Equipe de Shock ។




សញ្ញានេះសំរាប់សំគាល់ កងទ័ព MIKE FORCE ។




សញ្ញានេះសំរាប់សំគាល់ កងទ័ព MIKE FORCE ។

# AREAS OF OPERATION

